## ការបង្ខិតបង្ខំ (duress)

ករបង្ខិតបង្ខំ ជាប្រភេទនៃការដោះសារ (excuse) ដែលប្រភពនាំឲ្យមានការបង្ខិតបង្ខំ គឺមកពីមនុស្ស។ បទបញ្ជោថ្នាក់លើ គឺជាស្ថានភាពមួយនៃការបង្ខិតបង្ខំ។

ការដោះសារនេះ អាចត្រូវបានទទួលយកបាននៅពេលដែល មានការគម្រាមសម្លាប់ ឬបង្ករបួសស្នាមធ្ងន់ធ្ងរ ដែលនឹងកើតមានភ្លាមៗ (threat of imminent death) ហើយបុគ្គលទទួលរងនូវការបង្ខំ គ្មានជម្រើស (moral choice) ក្រៅពីប្រព្រឹត្តទង្វើល្មើស ដែលគេបង្ខំ។ តុលាការខ្លះ ប្រើពាក្យ "ការគម្រាមត្រូវតែពិត មិនអាចជៀសបាន និង ដែលនឹងត្រូវកើតឡើងភ្លាមៗ"។ ទង្វើ ដោយសារការបង្ខំ មិនត្រូវលើសពីអ្វី ដែលព្យាយាមជៀសផុតនោះឡើយ។ *មិនមានតុលាការណាមួយ នឹងផ្តន្ទាទោសបុគ្គល ដែលកាំភ្លើងមានគ្រាប់ ត្រូវបានភ្ជង់ចំក្បាល និង ត្រូវបានបង្ខំឲ្យទាញកៃកាំភ្លើង បាញ់គេទេ*។

បុគ្គលមិនអាចលើក ការបង្ខំ ជាការដោះសាររួចខ្លួនទេ ប្រសិនបើ គាត់ចូលរួមដោយស្ម័គ្រចិត្តក្នុងស្ថានភាពនាំឲ្យមានការបង្ខំនោះ។ នេះជាពិសេស ក្នុងករណីដែលគាត់ដឹង និងមានឆន្ទៈក្នុងការបំពានច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (international criminal law)។

សម្រាប់ការឆ្លើយតប សំណួរអាចនឹងត្រូវសួរថា តើច្បាប់រំពឹងនូវការឆ្លើយតបដូចម្តេច ក្នុងស្ថានភាពបង្ខំ? តើគេរំពឹងទេថា ជនល្មើស មិនខ្វល់ពីការគម្រាមដល់ជីវិតគាត់? ស្តង់ដារដែលត្រូវបានប្រើសម្រាប់វាស់វែងថា ការឆ្លើយតបសមហេតុផលឬមិន គឺមនុស្សមានហេតុផល។ នេះក្នុងខ្លឹមសារថា ប្រឈមនឹងកាលៈទេសៈនេះ មនុស្សមានស្ថានភាពដូចគ្នា ឆ្លើយតបយ៉ាងដូចម្តេច? (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 431-433)។

**ខ្លឹមសារបន្ថែម៖** ពាក្យថា Imminent សំដៅថាអ្វើមួយ នឹងកើតឡើងភ្លាម ដូចជា ការណ៍ដែលកាំភ្លើងកំពុងភ្ជង់លើក្បាលប្រពន្ធ គម្រាមប្តីបាញ់សំលាប់មនុស្ស ៥នាក់។ រួមផ្សំ ករណីដែលប្តីធ្លាប់ដឹង ថា បើមិនធ្វើតាម ជនគម្រាម ធ្លាប់សម្លាប់គេ នោះជាការពិត បើបដិសេធ គេពិតជាសម្លាប់ប្រពន្ធ។ ការគម្រាមនេះ គឺ Imminent ពិត និងមិនអាចជៀសបាន។ ស្ថានភាពនេះ ប្តីគ្មានជម្រើសទេ (no moral choice) ក្រៅពីសម្លាប់តាមការគម្រាម។ ទីនេះ វាទំនងជាមិនអាចទទួលយកបាន ដោយសារ សម្លាប់មនុស្ស មួយក្រុម ដើម្បីរក្សាជីវិតប្រពន្ធតែម្នាក់។ ជាដំណោះស្រាយ ប្តីនឹងត្រូវទទួលខុសត្រូវ នឹងមិនរួចផុតទាំងស្រុងពីការទទួលខុសត្រូវទេ (complete defense) ។ គាត់អាចទទួលស្ថានសម្រាលទោស។

ក្នុងករណីដដែល ប្ដីធ្លាប់ដឹងថា បើចូលក្នុងក្រុមនេះ អាចនឹងមាន ការគម្រាមសម្លាប់សមាជិកគ្រួសារ តែគាត់នៅតែចូលដោយស្ម័គ្រចិត្ត ដូចនេះ គាត់មិនអាចលើកការបង្ខំជាការដោះសារទេ។